**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ: ០៧១១/១០ ក.អ.ជ

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១០.

**រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

**ជម្រាបមក**

**លោក រម៉ាម ហ្លិន តំណាងសហគមន៍ជនជាតិដើមភាគតិច ចារ៉ាយ**

**ភូមិប្លង់ ឃុំប៉ាតេ ស្រុកអូរយ៉ាដាវ**

**កម្មវត្ថុ:** ស្តីពីការទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ចារ៉ាយ ភូមិប្លង់ ឃុំប៉ាតេ ស្រុកអូរយ៉ាដាវ

**យោង:**
- លិខិតចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការស្នើសុំទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ចារ៉ាយ ភូមិប្លង់ របស់លោក រម៉ាម ហ្លិន តំណាងសហគមន៍។
- លិខិតលេខ ១៨៩/១០ ល.អ.ខ ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ២០១០ ស្តីពីការទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ចារ៉ាយ ភូមិប្លង់ របស់អភិបាល នៃគណៈអភិបាលខេត្តរតនគីរី។
- លទ្ធផលវាយតម្លៃអត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ចារ៉ាយ ភូមិប្លង់ របស់ក្រុមការងារនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច នៃក្រសួងអភិវឌ្ឍន៍ជនបទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមលោកជ្រាបថា ក្រសួងអភិវឌ្ឍន៍ជនបទយល់ព្រមទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ចារ៉ាយ ភូមិប្លង់ ឃុំប៉ាតេ ស្រុកអូរយ៉ាដាវ ខេត្តរតនៈគីរី តាមសំណើ។ សហគមន៍ជនជាតិដើមភាគតិច ចារ៉ាយ ភូមិប្លង់ អាចប្រើប្រាស់លិខិតទទួលស្គាល់អត្តសញ្ញាណនេះ ក្នុងសកម្មភាពបម្រើដល់ផលប្រយោជន៍រួមរបស់សហគមន៍ ផលប្រយោជន៍សង្គម និងផលប្រយោជន៍ជាតិ តាមការចាំបាច់ស្របតាមគោលនយោបាយ ច្បាប់ បទបញ្ញា និងលិខិតបទដ្ឋានទាំងឡាយ នៃព្រះរាជាណាចក្រកម្ពុជា។

សូមលោក ទទួលនូវសេចក្តីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

ជា សុផារ៉ា

*ចម្លងជូន*
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងទេសចរណ៍
  "ដើម្បីជូនជ្រាប"
- សាលាខេត្តរតនគីរី
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តរតនគីរី
  "ដើម្បីមុខការ"
- ឯកសារកាលប្បវត្តិ

អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 884 539
ទូរសារ (855) 23 991 117 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com